១

# ឆវជាតក



*ព្រះសាស្តាកាលស្តេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធឆព្វគ្គិយភិក្ខុ បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា* **សព្វមិទំ ចរិមំ កតំ** *ដូច្នេះជាដើម ។*

*រឿងរ៉ាវបច្ចុប្បន្នមានមកដោយពិស្តារហើយ ក្នុងព្រះវិន័យ[១] ។ ប៉ុន្តែក្នុងជាតកនេះ ព្រះសាស្តាត្រាស់ហៅឆព្វគ្គិយភិក្ខុឲ្យចូលគាល់ ហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា អ្នកទាំងឡាយអង្គុយលើអាសនៈទាប សម្តែងធម៌ ដល់មនុស្សដែលអង្គុយលើ*

---

*១. ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ អង្គុយលើអាសនៈទាប ហើយសំដែងធម៌ដល់មនុស្សគ្មានជំងឺអង្គុយលើអាសនៈខ្ពស់ ត្រូវអាបត្តិទុក្កដ (វិនយបិដក មហាវិភង្គ សេក្ខិយកណ្ឌ ធម្មទេសនាបដិសំយុត្ត បាទុកវគ្គ នវមសិក្ខាបទ បិដកលេខ ៤ ទំព័រ ៤៩១) ។*

អាសនៈខ្ពស់ ពិតមែនឬ ? កាលឆព្វគ្គិយភិក្ខុទូលថា យ៉ាងនោះមែន ព្រះអង្គ, ព្រះសាស្ដា តិះដៀលភិក្ខុទាំងនោះ រួចព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការដែលអ្នកទាំងឡាយធ្វើការមិនគោរពចំពោះធម៌របស់តថាគតនេះ មិនគួរទេ, បោរាណកបណ្ឌិតទាំងឡាយ តិះដៀលបុគ្គលដែលអង្គុយលើអាសនៈទាប បង្រៀនមន្តខាងក្រៅ ហើយព្រះអង្គនាំយកអតីតនិទានមកថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិ ក្នុងនគរពារាណសី, ព្រះពោធិសត្វកើតក្នុងត្រកូលចណ្ឌាល ចម្រើនវ័យឡើងហើយ ស្វែងរកទ្រព្យសម្បត្តិ ។ ភរិយារបស់ព្រះពោធិសត្វ កើតពោគចាញ់កូន ឃ្លានផ្លែស្វាយ បានប្រាប់ព្រះពោធិសត្វថា បពិត្រស្វាមី ខ្ញុំចង់ហូបផ្លែស្វាយ ។

ព្រះពោធិសត្វពោលថា នែអូនសម្លាញ់ ក្នុងកាលនេះ មិនមានផ្លែស្វាយទេ បងនឹងនាំផ្លែអម្ពិលយ៉ាងណាមួយដទៃមកវិញ ។

ភរិយាពោលថា បពិត្រស្វាមី បើខ្ញុំបានស្វាយហូប ទើបរស់, បើមិនបានទេ ជីវិតរបស់ខ្ញុំ មិនរស់ទេ ។

ព្រះពោធិសត្វមានចិត្តស្រឡាញ់ប្រពន្ធ គិតថា តើអញបានផ្លែស្វាយអំពីទីណាហ្ន៎ ។ គាប់ចួនពេលនោះ ដើមស្វាយក្នុងឧទ្យានរបស់ស្ដេចក្រុងពារាណសី មានផ្លែជានិច្ច ។

ព្រះពោធិសត្វគិតថា អញនឹងនាំផ្លែស្វាយទុំអំពីឧទ្យាននោះ ដើម្បីឲ្យប្រពន្ធហូប បាត់ពោគចាញ់កូន ។ ក្នុងពេលយប់ លោកទៅកាន់ឧទ្យាន ឡើងដើមស្វាយ សួតាមមែក និងសម្ងឹងរកផ្លែស្វាយ ។ កាលលោកកំពុងរកមើល រាត្រីក៏កាន់តែងងឹតខ្លាំង ។ លោកគិតថា ប្រសិនបើអញចុះឥឡូវនេះ ពួកគេនឹងឃើញហើយចាប់អញចោទថា ជាចោរ អញនឹង

ចុះក្នុងពេលយប់ជ្រៅ ។ គ្រានោះ ពោធិសត្វឡើងទៅកាន់ប្រគាបមួយ ហើយពួនសម្ងំនៅទីនោះ ។

គ្រានោះ ព្រះបាទពារាណសីយាងចូលទៅក្នុងឧទ្យាន ដោយគិតថា យើងនឹងរៀនមន្តក្នុងសម្នាក់បុរោហិត រួចទ្រង់គង់លើអាសនៈខ្ពស់ទៀបគល់ដើមស្វាយ ប្រាប់ឲ្យអាចារ្យអង្គុយលើអាសនៈទាប ហើយទ្រង់រៀនទូវមន្ត ។ ព្រះពោធិសត្វដែលពួនសម្ងំនៅខាងលើ គិតថា ព្រះរាជានេះប្រកបដោយធម៌ ព្រះរាជាណាគង់លើអាសនៈខ្ពស់រៀនមន្ត, សូម្បីព្រាហ្មណ៍ក៏មិនប្រកបដោយធម៌ដែរ ព្រាហ្មណ៍ណាអង្គុយលើអាសនៈទាបបង្រៀនមន្ត, សូម្បីអញក៏មិនប្រកបដោយធម៌ដែរ បុគ្គលណាលុះក្នុងអំណាចមាតុគ្រាម មិនគិតជីវិតខ្លួនឯងមកលួចស្វាយនេះ ។ ព្រះពោធិសត្វចុះពីដើមស្វាយ ចាប់មែកសំយុងមួយឈរនៅរវាងស្តេចនិងបុរោហិតទាំងពីរនោះ ពោលថា បពិត្រមហារាជ ទូលព្រះបង្គំវិនាសហើយ, ព្រះអង្គវង្វេងហើយ, បុរោហិតស្លាប់ហើយ ។ កាលព្រះរាជាសួរថា ព្រោះហេតុអ្វី លោក ? ព្រះពោធិសត្វពោលគាថាទី ១ ថា

**សព្ពមិទំ ចរិមំ កតំ, ឧភោ ធម្មំ ន បស្សរេ;**
**ឧភោ បកតិយា ចុតា, យោ ចាយំ មន្តេជ្ឈាបេតិ;**
**យោ ច មន្តំ អធីយតិ។**

កិច្ចដែលយើងទាំងបីនាក់ ធ្វើហើយ ទាំងអស់នេះជាកិច្ចលាមក បុគ្គលណា (អង្គុយក្នុងទីទាប) បង្ហាញមន្ត ១ បុគ្គលណា (អង្គុយក្នុងទីខ្ពស់) រៀនទូវមន្ត ១ បុគ្គលទាំងពីរនាក់ (នោះ) មិនឃើញទូវបោរាណធម៌ផង បុគ្គលទាំងពីរនាក់ (នោះ) ឃ្លាតចាកធម៌ប្រក្រតី ។

*ពិតមែនហើយ ធម៌ឈ្មោះថាប្រក្រតី ដោយអំណាចនឹងការកើតឡើងជាគ្រាដំបូង ។ សមដូចពុទ្ធភាសិតថា*

ធម្មោ ហវេ បាតុរហោសិ បុព្វេ; បច្ឆា អធម្មោ ឧទបាទិ លោកេ។

*ធម៌បានកើតមុន អធម៌កើតក្រោយ ក្នុងលោក ។*

*(សុត្តន្តបិដក ជាតក ឯកាទសកនិបាត ធម្មទេវបុត្តជាតក បិដកលេខ ៥៩ )*

*ព្រាហ្មណ៍ស្តាប់ពាក្យនោះហើយ ក៏ពោលគាថាទី ២ ថា*

**សាលីនំ ឱទនំ ភុញ្ជេ, សុចឹ មំសូបសេចនំ;**
**តស្មា ឯតំ ន រោចេមិ, ធម្មំ ឥសីហិ សេវិតំ។**

*ខ្ញុំបរិភោគបាយស្រូវសាលី (ដ៏ស) ស្អាត (របស់ស្តេចនេះ) លាយដោយសាច់ ហេតុនោះ បានជាខ្ញុំមិនសេពគប់នូវធម៌ ដែលពួកឥសីសេពគប់ហើយនោះទេ ។*

*ព្រះពោធិសត្វស្តាប់ពាក្យនោះហើយ ពោល ២ គាថាដទៃទៀតថា*

**បរិព្ពជ មហា លោកោ, បចន្តញ្ញេបិ បាណិនោ;**
**មា តំ អធម្មោ អាចរិតោ, អស្មា កុម្ភមិវាភិទា។**

*អ្នកជៀសចេញពីទីនេះទៅ លោកនេះក៏ធំទូលាយ ពួកសត្វឯទៀត តែងស្វែងរកអាហារ (ផ្សេង) ដែរ អ្នកកុំប្រព្រឹត្តអធម៌ ដូចជាថ្មដែលបំបែកនូវឆ្នាំងឡើយ ។*

**ធិរត្ថុ តំ យសលាភំ, ធនលាភញ្ច ព្រាហ្មណ;**
**យា វុត្តិ វិនិបាតេន, អធម្មចរណេន វា។**

ម្នាលព្រាហ្មណ៍ យើងសូមតិះដៀលនូវការបានយសនិងការបានទ្រព្យ ព្រោះការប្រព្រឹត្តបំផ្លាញខ្លួន ឬដោយកិរិយាប្រព្រឹត្តអធម៌ ។

លំដាប់នោះ ព្រះរាជាជ្រះថ្លាចំពោះធម្មកថា របស់ព្រះពោធិសត្វ ទ្រង់សួរថា នែបុរសដ៏ចម្រើន តើអ្នកមានជាតិអ្វី ? ព្រះពោធិសត្វទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំជាចណ្ឌាល ។

ព្រះរាជាត្រាស់ថា នែបុរសដ៏ចម្រើន ប្រសិនបើអ្នកដល់ព្រមដោយជាតិ យើងនឹងប្រទានរាជសម្បត្តិដល់អ្នក ប៉ុន្តែចាប់ពីថ្ងៃនេះទៅ យើងជាស្តេចក្នុងវេលាថ្ងៃ ចំណែកអ្នកចូរជាស្តេចក្នុងវេលាយប់ចុះ ដូច្នេះហើយ ព្រះរាជាដោះកម្រងផ្កា ជាគ្រឿងប្រដាប់ករបស់ព្រះអង្គ មកបំពាក់ករបស់ព្រះពោធិសត្វ ធ្វើព្រះពោធិសត្វឲ្យជាអ្នកគ្រប់គ្រងនគរ ។ កម្រងផ្កានេះ គឺជាកម្រងផ្កាពណ៌ក្រហម ដែលវង្សត្រកូលទុកជាគ្រឿងប្រដាប់ករបស់អ្នកគ្រប់គ្រងនគរ ។ ចាប់ពីពេលនោះមក ព្រះរាជាបានតាំងនៅក្នុងឱវាទ របស់ព្រះពោធិសត្វ ព្រះអង្គធ្វើសេចក្តីគោរពចំពោះអាចារ្យ គង់លើអាសនៈទាប ហើយរៀននូវមន្ត ។

ព្រះសាស្តានាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា

**តទា រាជា អានន្ទោ អហោសិ** ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទ

**ចណ្ឌាលបុត្តោ បន អហមេវ អហោសឹ** ចំណែកកូនចណ្ឌាល គឺ **តថាគត** នេះឯង ។

ឆវជាតក ចប់ ៕

(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ចតុក្កនិបាត កាលិង្គវគ្គ បិដកលេខ ៥៨ ទំព័រ ១៩៤)
ថ្ងៃ សៅរ៍ ១០ កើត ខែ កត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស. ១៣៨០ ម.ស. ១៩៤០
ថ្ងៃទី ១៧ ខែ វិច្ឆិកា ព.ស. ២៥៦២ គ.ស.២០១៨
ដោយស.ដ.វ.ថ.